ទស្សនៈអ្នកនិពន្ធ

វ៉ុល៤, លេខ១០, ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

# ៥៥ឆ្នាំរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

ទាន សំណាង* និង រស់ សយម្ភូ**

នៅឆ្នាំ១៩៦៧ អាស៊ានបានលេចជារូបរាង ដោយពេលនោះ មានប្រទេសតែប្រាំប៉ុណ្ណោះជាសមាជិក ដែលមានជាអាទិ៍ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន និងថៃ។ បើពិនិត្យមើលពីគោលបំណងវិញ អាស៊ាននាពេលនោះ គឺជាការរួបរួមគ្នា ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃសង្គ្រាមត្រជាក់ ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់ជាក់ស្តែង ចេញពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ រវាងប្រទេសមហាអំណាច។ ជាសន្សឹមៗ ទោះមិនមានមហិច្ឆតាទៅគ្រប់គ្រង ឬឈ្លានពានរដ្ឋណាមួយ ក៏អាស៊ាន បាននិងកំពុងក្លាយជាតួឯកមួយយ៉ាងសំខាន់នៅក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។ ខ្សែភ្នែកជាច្រើន បាននិងកំពុងសម្លឹងមកអាស៊ាន ហើយកាន់តែច្រើនថែមទៀតក្នុងឆ្នាំ២០២២ នេះ ដែលកម្ពុជា ជាប្រធានអាស៊ានប្តូរវេន។ ជាធម្មតានៅពេលដែលមានការលេចធ្លោ ឬឡើងខ្ពស់ត្រដែតកាន់តែខ្ពស់ គឺកាន់តែប្រឈមជាមួយនឹងភ្លៀងខ្យល់។ល។ និយាយមួយបែបទៀត ការចោលភ្នែកសម្លឹងមកកាន់អាស៊ាននេះ អាចជាបញ្ហាប្រឈមផង និងអាចជាកាលានុវត្តភាពផង។ នៅក្នុងដំណើរជាងកន្លះសតវត្សរ៍របស់អាស៊ានមកទល់នឹងបច្ចុប្បន្ន គឺតែងតែមានការញ៉ាំញីទៅដោយបញ្ហាប្រឈមប្រពៃណី និងមិនមែនប្រពៃណី ក៏ដូចជាការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច។ ការណ៍នេះ សូមកុំមើល ឬមានអារម្មណ៍ទុទិដ្ឋិនិយមជាមួយអាស៊ាន ផ្ទុយទៅវិញគួរពិចារណាអំពីទិដ្ឋភាពសាកលជារួម។ ថ្វីត្បិតសង្គ្រាមលោកលើកទី១ សង្គ្រាមលោកលើកទី២ និងសង្គ្រាមត្រជាក់បានបិទបញ្ចប់ក៏ពិតមែន តែការប្រជែងអំណាចរវាងរដ្ឋធំៗ ដែលមានឥទ្ធិពលនៅតែបន្ត ហើយជានិច្ចកាលតែងតែបង្កព្យុះភ្លៀង និងព្យសនកម្មជារឿយៗមកលើរដ្ឋដែលជាអំណាចកណ្តាល និងរដ្ឋតូច។ ផ្អែកលើទិដ្ឋភាពទាំងនេះ មជ្ឈភាពអាស៊ានហាក់ទទួលរងការគំរាមកំហែង។ ប្រសិនបើដូច្នោះមែន តើបញ្ហាអ្វីខ្លះដែលកើតមាន និងកំពុងធ្វើទុក្ខបុកម្នេញអាស៊ាន? តើកត្តាអ្វីខ្លះដែលនាំឱ្យអាស៊ានរក្សាសាមគ្គីភាព និងមជ្ឈភាពរបស់ខ្លួន? ហើយកម្ពុជាក្នុងនាមរដ្ឋជាសមាជិក និងជាប្រធានប្តូរវេនរបស់អាស៊ាន ឆ្នាំ២០២២ បានចូលរួមអ្វីខ្លះក្នុងការកសាងសហគមន៍នេះ?

## បញ្ហាប្រឈមសម្រាប់អាស៊ាន

ដូចបានរៀបរាប់ខាងលើ អាស៊ានបានឆ្លងកាត់ការលំបាកជាច្រើនរហូតមកទល់នឹងគម្រប់ខួប ៥៥ ឆ្នាំនេះ។ ទោះជាយ៉ាងនេះក្តី អត្ថបទទស្សនៈនេះ នឹងលើកមកបង្ហាញត្រឹមអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយប៉ុណ្ណោះ។ បញ្ហាលេចធ្លោនានា ដែលបង្កជាការព្រួយបារម្ភសម្រាប់ពិភពលោកនារយៈពេលថ្មីៗនេះ ដូចជាសង្គ្រាមអ៊ុយក្រែន-រុស្ស៊ី ភាពតានតឹង

---

* **ឯកឧត្តម ទាន សំណាង** គឺជាប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

****លោក រស់ សយម្ភូ** គឺជាអ្នកស្រាវជ្រាវជំបូងនៃសមាគមសាលាត្រាជូ។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

នៅឧបទ្វីបកូរ៉េ បញ្ហាសមុទ្រចិនខាងត្បូង ការវិវឌ្ឍឆ្លងច្រក
សមុទ្រនៅតំបន់ក្បែរអាស៊ាន ស្ថានភាពនៅមីយ៉ាន់ម៉ា ជាដើម
បានបង្កប់នូវរបៀបវារៈនយោបាយ ឬការប្រជែងភូមិសាស្ត្រ
នយោបាយ ពិសេសដោយប្រទេសមានអំណាច។ បញ្ហាទាំង
អស់នេះ គឺជាវិញ្ញាសាដ៏គ្រោះថ្នាក់ ក្នុងការល្បងសមត្ថភាព
និងសាមគ្គីភាពអាស៊ាន។ ជាការពិត ចំណោទបញ្ហាខាងលើ
បានផ្តល់នូវសម្ពាធដល់អាស៊ាន ប៉ុន្តែការព្រួយបារម្ភចំពោះ
បញ្ហាខាងលើនេះ ប្រហែលជាមិនបានរំលេចអំពីដំណើរការ
សមាហរណកម្ម និងនិម្មាបនកម្មអាស៊ាននោះទេ។ ជាកត្តា
សត្យានុម័តិ បញ្ហាភូមិសាស្ត្រនយោបាយនឹងនៅតែបន្តលង
បន្លាចអាស៊ាន ក៏ប៉ុន្តែវាមិនមែនជារឿងថ្មីទេ ពីព្រោះអាស៊ាន
បានជួបបញ្ហានេះ ៥៥ឆ្នាំមកហើយ បើទោះបីមិនដូចគ្នា
ទាំងស្រុងក្តី ក៏អាស៊ានល្មមមានភាពស៊ាំ និងបទពិសោធន៍
ក្រាស់ក្រែល ក៏ដូចជាការយល់ចិត្តរវាងគ្នា និងគ្នាមួយកម្រិត។
ម្យ៉ាងវិញទៀត សូម្បីតែសហភាពអឺរ៉ុប ដែលជាទូទៅត្រូវបាន
ចាត់ទុកថាជាអង្គការតំបន់ពេញលេញ សម្បូណ៌ទៅដោយ
បទដ្ឋានគតិយុត្តចាក់ស្រេះ ក៏គង់នៅមានការរង្គោះរង្គើ។
ដោយឡែកសម្រាប់អាស៊ាន ទោះបីជាមានបញ្ហាភូមិសាស្ត្រ
នយោបាយ និងការបង្កអស្ថិរភាពដោយប្រទេសមានអំណាច
ក្តី អាស៊ានមិនបានបោះបង់ឆន្ទៈក្នុងការដោះស្រាយបញ្ហា
ប្រឈមរួមនោះឡើយ។ ជាក់ស្តែង ទោះបីជាវិបត្តិកូវីដ១៩
បានបង្អាក់សកម្មភាព និងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ក៏ប៉ុន្តែ
ជាមួយនឹងមជ្ឈភាពអាស៊ាន អង្គការតំបន់នេះកាន់តែបន្ត
សមាហរណកម្មខ្លួន ដោយសម្រេចបានដោយជោគជ័យ
កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់
(RCEP)។ នៅក្នុងបរិបទសេដ្ឋកិច្ចនេះទៀតសោត អាស៊ាន
គឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចដ៏សំខាន់ និងជាដៃកធក់ពាណិជ្ជ-
កម្មយ៉ាងទាក់ទាញ ក្នុងឋានៈជាមហាអំណាចសេដ្ឋកិច្ចទី៣
នៅអាស៊ី និងទី៥ក្នុងពិភពលោក ជាមួយនឹងផលិតផល
សរុបក្នុងតំបន់ប្រមាណ ៣ ទ្រីលានដុល្លារ។ មកត្រឹមចំណុច
នេះយើងបានឃើញហើយថា អាស៊ានមិនមែនជាអង្គការ
តំបន់ដែលរង់ចាំតែដោះស្រាយ ឬជាស្ថាប័នដើម្បីប្រឈម
អំណាចគ្នានោះទេ ហើយរឹតតែមិនមែនជាកូនអុករបស់
មហាអំណាចណាមួយទេ ប៉ុន្តែជានីតិបុគ្គលពេញលេញ
ស្មើមុខ ស្មើសិទ្ធិ និងឯករាជ្យ អនុលោមតាមជំពូកទី២ នៃ
ធម្មនុញ្ញអាស៊ាន។ គួរឱ្យកត់សម្គាល់ផងដែរថា នៅក្នុង
សេចក្តីប្រកាសរួមរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន
លើកទី៥៥ (Joint Communiqué) បានបង្ហាញយ៉ាង
ច្បាស់ថា អាស៊ានមិនមែនជាតំបន់ដែលចង់បាន ឬចង់ឱ្យ
មានការប្រទូសរ៉ាយគ្នានោះទេ។ តាមរយៈសេចក្តីប្រកាស
រួមខាងលើ អាស៊ាន បាននិងកំពុងបោះជំហាន ក៏ដូចជា
ប្រើប្រាស់លទ្ធភាព ដើម្បីជំរុញទំនាក់ទំនងស្និទ្ធស្នាល និង
កិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលក្នុងតំបន់ និងដៃគូ
ខាងក្រៅទូទាំងពិភពលោក ដើម្បីរក្សាសន្តិភាព សន្តិសុខ
វិបុលភាព និងការអភិវឌ្ឍប្រទេសជាតិឱ្យស្ថិតស្ថេរយូរអង្វែង
លើគ្រប់វិស័យ។ អាស៊ាន គឺមានឯករាជ្យ ម្ចាស់ការ។ អាស៊ាន
មិនត្រូវការការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនោះទេ ហើយ
ពិសេស មិនមានអ្នកណាខ្វល់ខ្វាយពីសុខុមាលភាព សុខ
សន្តិភាព និងការអភិវឌ្ឍអាស៊ានជាងអាស៊ានខ្លួនឯងនោះ
ឡើយ។ សេចក្តីប្រកាសរួមខាងលើ បានបញ្ជាក់យ៉ាងច្បាស់
ពីកិច្ចការ ជាច្រើនដែលអាស៊ានត្រូវគិតគូរដោយមិនចំពោះ
ដូចជា បន្តធ្វើការរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩
បន្តធ្វើការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ បន្តគិតគូរ និងសហ-
ប្រតិបត្តិការចំពោះការអភិវឌ្ឍទីក្រុងវៃឆ្លាត ក៏ដូចជា សហ-
ប្រតិបត្តិការលើវិស័យអប់រំ យុវជន កីឡា សុខាភិបាល
ព័ត៌មាន ពលកម្ម បរិស្ថាន សេវាសាធារណៈ វប្បធម៌ យេន
ឌ័រ កសិកម្ម កិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ
ជាមួយដៃគូក្រៅតំបន់ សន្តិសុខប្រព័ន្ធអ៊ិនធឺណិត ឧក្រិដ្ឋកម្ម
ឆ្លងដែន -ល- ដែលទាំងនេះបានចារឹកនៅក្នុងសសរស្តម្ភ
ទាំងបីរបស់ អាស៊ាន គឺសសរស្តម្ភនយោបាយ-សន្តិសុខ
សសរស្តម្ភសេដ្ឋកិច្ច និងសសរស្តម្ភសង្គម-វប្បធម៌។ ជារួម
អាស៊ានបានបង្កើតឡើងដើម្បីការពារ និងលើកកម្ពស់
កំណើនដោយសន្តិភាព និងលើកកម្ពស់សុខុមាលភាព
របស់ប្រជាជនក្នុងតំបន់ ដើម្បីកំណើនរួម។ អាស៊ានធ្វើការ
ដោយកុងសង់ស៊ីស មូលមតិគ្នា ជាមួយនឹងការគោរពគ្នាទៅ
វិញទៅមក ចំពោះឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី

សមភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ហើយគោលការណ៍ទាំងនេះ មានចែងក្នុងធម្មនុញ្ញអាស៊ាន ក្នុងស្មារតីសាមគ្គីភាពដើម្បីកំណើនរួម និងដើម្បីពុះពារហែលឆ្លងកាត់ព្យុះភ្លៀងនៃភូមិសាស្ត្រនយោបាយ។

## មាគ៌ាអាស៊ាន

ការយល់ដឹងពីមាគ៌ាអាស៊ានមានសារសំខាន់ណាស់ ពិសេសគោលការណ៍ដែលរៀបរាប់ខាងលើ ដូចជា កុងសង់ស៊ីស ការគោរពគ្នាទៅវិញទៅមកចំពោះឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សមភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ដែលជាគោលការណ៍គ្រឹះក្នុងធម្មនុញ្ញអាស៊ាន។ អស់រយៈពេល ៥៥ឆ្នាំកន្លងទៅ មាគ៌ាអាស៊ាន បង្ហាញនូវសារសំខាន់របស់ខ្លួនកាន់តែខ្លាំងឡើង។ អាស៊ានតែងតែទទួលរងការមើលងាយ ក៏ដូចជាមិនត្រូវបានផ្តល់តម្លៃដោយតួអង្គខាងក្រៅ ដោយសារហេតុផលជាច្រើនដែលហេតុផលមួយក្នុងចំណោមនោះ គឺថានៅមុនបង្កើតធម្មនុញ្ញអាស៊ានឆ្នាំ២០០៧ អាស៊ានមិនទាន់មាននីតិបុគ្គលភាពនោះទេ គឺត្រឹមតែជាក្រុមនៃប្រទេស ដែលធ្វើការរួមគ្នាបែបធូររលុងប៉ុណ្ណោះ។ ដោយសារតែស្ថានភាពនេះហើយ ទើបបានជាគេពេបជ្រាយថា អាស៊ានបានត្រឹមតែមាត់ ឬជាវេទិកាសម្រាប់ជជែកគ្នាតែប៉ុណ្ណោះ។ ជាបន្តបន្ទាប់ អាស៊ានបានប្រែក្លាយខ្លួនបន្តិចម្តងៗ ជាអង្គការតំបន់ដែលមាននីតិបុគ្គលភាព ហើយទទួលបានការចាប់អារម្មណ៍ ធ្វើជាដៃគូជាមួយរដ្ឋនានា។ ការណ៍នេះបង្ហាញថា អាស៊ានគោរពគ្នាទៅវិញទៅមក។ អាស៊ានយល់ថាបើមានការចាប់បង្ខំ ឬជ្រៀតជ្រែកនោះ អាស៊ាននឹងមិនគង់វង្សឡើយ ហើយកុងសង់ស៊ីសនៅតែបន្តជាស្នូលក្នុងការសម្រេចចិត្ត។ ការធ្វើបែបនេះអាចមានន័យថា គ្រប់រដ្ឋជាសមាជិកអាស៊ានគឺស្មើភាព និងស្មើសិទ្ធិ មិនមានប្រទេសតូច ឬធំ រដ្ឋមួយមានសំឡេងមួយដូចគ្នា និងមានតម្លៃស្មើគ្នា។ នៅក្នុងបរិបទអាស៊ាន ការណ៍នេះអាចចៀសវាងការបែងចែករវាងប្រទេសក្រ-មាន ឬតូច-ធំនៅក្នុងតំបន់។ នៅក្នុងការថែរក្សាមជ្ឈភាពរបស់ខ្លួន អាស៊ានមិនចង់ទៅដឹកមុខនរណានោះទេ ហើយអាស៊ានក៏មិនទៅហាមឃាត់នរណា ឬទៅប្រឈមមុខជាមួយរដ្ឋ ឬក្រុមណាមួយឡើយ។ និយាយមួយបែបទៀត អាស៊ានមានយន្តការធ្វើការមួយដែលសំដៅលើសុទិដ្ឋិនិយម កំណើនរួម និងសហប្រតិបត្តិការ។ ចំពោះមជ្ឈភាពអាស៊ាន អាចមានការបកស្រាយថាអាស៊ាន គឺជាការផ្តល់តម្លៃឱ្យអាស៊ាន និងគោលការណ៍បទដ្ឋានគតិយុត្តអាស៊ាន។ ក្នុងន័យនេះ ដើម្បីគោរពមជ្ឈភាពអាស៊ាន រដ្ឋជាដៃគូ ឬរដ្ឋដែលមានបំណងធ្វើសហប្រតិបត្តិការជាមួយអាស៊ាន គួរកុំមានបំណងបំបែកបំបាក់អាស៊ាន ខណៈរដ្ឋជាសមាជិកអាស៊ាន ក៏គួរមានការប្រុងប្រយ័ត្ន ចំពោះកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទាំងឡាយណា ដែលមានលក្ខណៈប្រកួតប្រជែង ឬប្រឈមមុខ ដែលនឹងនាំឱ្យអាស៊ានមានការបែកបាក់ ឬផុយស្រួយ។ ជាឧទាហរណ៍ អាស៊ានមិនបានដឹកនាំគ្រប់យន្តការនោះទេ ប៉ុន្តែកំណើនរួម និងសហប្រតិបត្តិការក្នុងគោលដៅពង្រឹង និងពង្រីកសមត្ថភាព សាមគ្គីភាព និងភាពធន់ គឺមានភាពចាំបាច់ ហើយអាស៊ានបាននិងកំពុងធ្វើសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអនុតំបន់ជាច្រើនផងដែរ ដែលមានដូចជាយន្តការ Ayeyawady-Chao Phraya-Mekong Economic Cooperation Strategy (ACMECS), Brunei Darussalam-Indonesia-Malaysia-Philippines East ASEAN Growth Area (BIMP-EAGA), Indonesia-Malaysia-Thailand Growth Triangle (IMT-GT) និង Singapore-Johor-Riau (SIJORI) Growth Triangle ជាដើម ដែលទាំងអស់នេះ គឺមានចែងក្នុងសេចក្តីប្រកាសរួមរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ ត្រង់វាក្យខណ្ឌ ២៥ និង២៦។ អាស៊ានមកទល់ពេលនេះបានប្រើពេលជាង៥ទស្សវត្សរ៍ក្នុងការធ្វើសមាហរណកម្ម និងអភិវឌ្ឍតំបន់។ អាស៊ាននឹងត្រូវបន្តដំណើរជាសម្ព័ភាពរបស់ខ្លួន ជាពិសេសដើម្បីបង្កើតចក្ខុវិស័យ សម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ ដើម្បីចៀសវាងឥទ្ធិពលបំបែកបំបាក់ពីខាងក្រៅ។ ក្នុងន័យនេះ ទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ត្រូវបានបង្កើតឡើងដើម្បីបង្ហាញមជ្ឈភាព និងអព្យាក្រឹតអាស៊ាន សំដៅធ្វើយ៉ាងណាធ្វើឱ្យតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ប្រកបដោយសហប្រតិបត្តិការ មិនមែនជាទីតាំងប្រកួតប្រជែងគ្នានោះទេ ប៉ុន្តែជាតំបន់ដែលមានការសន្ទនា និងកិច្ចសហ-

ប្រតិបត្តិការ ជាតំបន់មានសន្តិភាព ការអភិវឌ្ឍ និងវិបុលភាព សម្រាប់ទាំងអស់គ្នា។ ទាំងអស់នេះ គឺអនុលោមតាមបទដ្ឋានគតិយុត្តដែលមានស្រាប់នៅក្នុងតំបន់ ក្នុងការរក្សាមជ្ឈភាពអាស៊ាន ពិសេសគឺមាគ៌ាអាស៊ាន។ ដូច្នេះពហុភាគីនិយមទាំងឡាយណាដែលមានលក្ខណៈតទល់ ឬប្រឈមមុខ គប្បីត្រូវមានការប្រុងប្រយ័ត្ន។ អ្វីដែលសំខាន់នោះសេចក្តីប្រកាសស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន ឆ្នាំ១៩៧១ បានបង្ហាញស្មារតីសន្តិភាពនិយម ពិសេសលើកកម្ពស់ និងលើកតម្កើងស្មារតីសាមគ្គីភាពអាស៊ាន។

## កម្ពុជា និងអាស៊ាន

មកទល់ឆ្នាំ២០២២នេះ កម្ពុជានៅបន្តជាសមាជិកកូនពៅរបស់អាស៊ាន។ ការធ្វើសមាហរណកម្មតំបន់ គឺមានសារៈប្រយោជន៍ និងសារសំខាន់ណាស់ ដែលប្រមុខរាជរដ្ឋាភិបាលតែងពន្យល់ជារឿយៗលើកត្តា ៤យ៉ាង គឺ (១) គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង (២) គោលការណ៍កុងសង់ស៊ីស និងស្មារតីសហគមន៍ ស្មើសិទ្ធិ ស្មើភាពមិនថាប្រទេសតូច ឬធំ (៣) ពង្រឹង និងពង្រីកសេដ្ឋកិច្ចតាមរយៈការធ្វើសមាហរណកម្មតំបន់ និង (៤) ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរបស់កម្ពុជា។ ក្នុងភាពជាប្រធានអាស៊ានរបស់កម្ពុជា កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើកទី៥៥ កន្លងទៅ បានបង្ហាញអំពីភាពចាំបាច់ក្នុងការរក្សាមជ្ឈភាពអាស៊ាន ពិសេសគឺភាពធន់ ដើម្បីឆ្លើយតបនឹងព្យសនកម្មនៃបញ្ហាមួយចំនួន ដូចជា សង្គ្រាមអ៊ុយក្រែន-រុស្ស៊ី ភាពតានតឹងនៅឧបទ្វីបកូរ៉េ បញ្ហាសមុទ្រចិនខាងត្បូង ការវិវឌ្ឍឆ្លងច្រកសមុទ្រនៅតំបន់ក្បែរអាស៊ាន ស្ថានភាពនៅមីយ៉ាន់ម៉ាជាដើម។ ការចេញសេចក្តីប្រកាសរួម បង្ហាញយ៉ាងច្បាស់ពីតម្រូវការមជ្ឈមណ្ឌលនៃសាមគ្គីភាពរវាងបណ្តារដ្ឋ។ ក្នុងនោះ កម្ពុជាបានដើរតួនាទីសម្របសម្រួលយ៉ាងសំខាន់ ដើម្បីឱ្យរដ្ឋមានជម្លោះអាចចរចាពិភាក្សា និងអង្គុយជាមួយគ្នាបាន។ កត្តាប្រវត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា ការប្រកួតប្រជែងយកចាញ់-ឈ្នះ និងការបង្កជាអស្ថិរភាព ឬសង្គ្រាម មិនបាននាំមកនូវសុខមាលភាព ការអភិវឌ្ឍ និងវិបុលភាពនោះទេ។ ជាមួយគ្នានេះ កម្ពុជាក៏មានចំណែកចូលរួមក្នុងការបង្កើតទស្សនវិស័យអាស៊ាន ស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ដើម្បីសំយោគយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកនានាឱ្យមកជាយន្តការរួមមួយដែលមានតម្លាភាព ដើម្បីជាលទ្ធផលផ្លែផ្កាសម្រាប់អាស៊ានទាំងមូល ដែលមិនមែនជានិន្នាការកាន់ជើង ឬប្រឈមមុខជាមួយដៃគូណាមួយឡើយ។ អាស៊ានបានធ្វើការសំយោគទាំងអស់នូវរាល់គំនិតផ្តួចផ្តើមនៅក្នុងតំបន់ជាច្រើនរួមមាន *«ខ្សែក្រវាត់ និងផ្លូវ (BRI)» «គោលនយោបាយធ្វើសកម្មភាពទិសខាងកើត (Act East Policy)» «គោលនយោបាយសម្លឹងមកទិសខាងត្បូង (The New Southern Policy)»* -ល- ដើម្បីឱ្យអាស៊ានទទួលផលប្រយោជន៍ ក៏ដូចជា ដើម្បីធានាមជ្ឈភាពខ្លួនស្របតាមមាគ៌ាអាស៊ាន។

ក្រោមភាពជាប្រធានអាស៊ានរបស់កម្ពុជា ក៏ដូចជាក្នុងស្មារតីមជ្ឈភាពអាស៊ាន និងមាគ៌ាអាស៊ាន ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ក៏អង្គការតំបន់មួយនេះ បាននិងកំពុងបោះជំហានទៅមុខ។ នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើកទី៥៥ គេឃើញមានការបន្ត និងប្រាស្រ័យទាក់ទង រវាងកូរ៉េទាំងពីរ ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការកសាងទំនុកចិត្ត។ មួយវិញទៀត បញ្ហាសមុទ្រចិនខាងត្បូង ក៏មានការវិវឌ្ឍមួយចំនួន ដូចជាការបន្តចរចាលើក្រមប្រតិបត្តិសម្រាប់ភាគីជម្លោះសមុទ្រចិនខាងត្បូង (COC) ដែលឆ្លុះបញ្ចាំងពីឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រដ្ឋជាសមាជិកអាស៊ានក្នុងការសម្របសម្រួល និងរដ្ឋជាភាគីជម្លោះ ក្នុងការរក្សាស្ថិរភាពគ្រប់គ្រងតំបន់ដោយសន្តិវិធី និងធានាថាដំណោះស្រាយជម្លោះ គឺផ្អែកលើច្បាប់អន្តរជាតិ ដែលមានជាអាទិ៍ UNCLOS។ បើពិនិត្យលើបញ្ហាមីយ៉ាន់ម៉ាវិញ ថ្វីត្បិតមិនទាន់មានការវិវឌ្ឍគួរឱ្យកត់សម្គាល់យ៉ាងណាក្តី ប្រេសិតពិសេសរបស់អាស៊ានសម្រាប់បញ្ហាមីយ៉ាន់ម៉ា បានបង្កើត និងខិតខំក្នុងការអនុញ្ញាត

ឱ្យមានក្របខ័ណ្ឌសម្រាប់ដំណើរការចរចា និងជំនួយមនុស្សធម៌ ដែលទាំងអស់នេះ គឺជាសុទិដ្ឋិនិយមមួយសម្រាប់អនាគត ដោយអភិក្រមប្រាកដនិយម និងជាក់ស្តែងមួយ គួរទទួលយក និងទទួលស្គាល់។ យើងអាចសួរជាសំណួរត្រលប់មកវិញថា មកទល់ពេលនេះក្រៅពីអាស៊ាន តើមានរដ្ឋ និងអង្គការណាខ្លះ អាចកែប្រែស្ថានការណ៍នៅមីយ៉ាន់ម៉ាបាន?

សរុបសេចក្តីមក ប្រការដែលយល់ថាអាស៊ានជាស្ថាប័នមិនប្រាកដប្រជា ឬជាស្ថាប័នមិនមានអំណាច គឺមានន័យថា មិនយល់អំពីបុព្វហេតុនៃការបង្កើតអាស៊ាននោះទេ។ អាស៊ានមិនចង់ទៅត្រួតត្រាខ្លាំងក្លាជាក់នរណាទេ ប៉ុន្តែអាស៊ានមានគោលដៅ និងរបៀបធ្វើការរបស់អាស៊ាន។ គោលដៅនោះគឺ អាស៊ានត្រូវបន្តដំណើរការកសាងសហគមន៍អាស៊ាន ដោយបំពេញគោលបំណង និងសកម្មភាពសំខាន់ៗ ដែលបានព្រមព្រៀងគ្នា ដូចដែលបានបញ្ជាក់នៅក្នុងផែនការកសាងសហគមន៍អាស៊ានទាំងបី ក៏ដូចជាបទដ្ឋានគតិយុត្តដែលមានសម្រាប់តំបន់។ ថ្វីត្បិតតែបញ្ហាភូមិសាស្ត្រនយោបាយ ឬបំណងរុញឱ្យរដ្ឋជាសមាជិកអាស៊ានមានការប្រឈមមុខដាក់គ្នានៅតែបន្តមាន ក៏ប៉ុន្តែជាលក្ខណៈជាក់ស្តែង អាស៊ានអាចយល់បានថា ការប្រឈមមុខដាក់គ្នាមិនបានផ្តល់ប្រយោជន៍ ឬវិបុលភាពឡើយ គឺមានតែសោកនាដកម្មប៉ុណ្ណោះ។ អាស៊ានត្រូវយល់ និងបន្តរក្សាគុណតម្លៃខ្លួន សាមគ្គីគ្នា ផ្អែកលើមាគ៌ាអាស៊ាន និងមជ្ឈភាពអាស៊ាន ក្នុងការហែលឆ្លងនូវព្យុះភ្លៀងភូមិសាស្ត្រនយោបាយ។ អត្ថបទនេះ សូមបញ្ចប់ជាមួយសុភាសិត «***ឃើញដំរីជុះ កុំជុះតាមដំរី***» ដោយសូមឱ្យអ្នកអានត្រិះរិះពិចារណាតាមការគួរ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
First Floor, Unit D1, The Kampus Building, 502h Preah Monivong Blvd (93), Phnom Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center